# របាយការណ៍អតិផរណាប្រចាំខែកញ្ញា ឆ្នាំ២០១០
# សម្រាប់កិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុលើកទី១៨

ភ្នំពេញ ថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ២០១០

## I. ស្ថានភាពអតិផរណាខែកញ្ញា ឆ្នាំ២០១០




អតិផរណាខែលើខែ ក្នុងខែកញ្ញានេះ មានអត្រាកំណើន ០,៧% ដែលជាកម្រិតវិជ្ជមានជាប់ៗគ្នាក្នុងរវាង៣ខែ ពោលគឺពី អត្រា ០,៥% និង០,៩% នាខែកក្កដានិងខែសីហារៀងគ្នា បន្ទាប់ពីមានអត្រាអវិជ្ជមាន -០,០៣% កាលពីខែមិថុនា ។ សូមកត់សម្គាល់ថាអត្រាអតិផរណាមធ្យមប្រចាំខែក្នុងអំឡុង ៩ ខែ ពីដើមឆ្នាំរហូតមកទល់ពេលនេះមានកម្រិត ០,៣% ដែលទាបជាងអត្រាអតិផរណាមធ្យមប្រចាំខែនារយៈពេលដូចគ្នានៃឆ្នាំមុនៗ ពោលគឺ ០,៧% ឆ្នាំ ២០០៩ ២,៣% ឆ្នាំ ២០០៨ និង ១,១% ឆ្នាំ ២០០៧ ។ ការណ៍នេះបង្ហាញថា ជាទូទៅ ស្ថានភាពអតិផរណាឆ្នាំ ២០១០ នេះមានស្ថិរភាពប្រសើរជាងគ្រាដូចគ្នាក្នុងរយៈ៣ឆ្នាំកន្លងមក ដែលអត្រាអតិផរណាមានការប្រែប្រួលច្រើនរវាងខែនីមួយៗ ។ ទាំងនេះជាការឆ្លុះបញ្ចាំងពីភាពនឹងនរនៃថ្លៃទំនិញក្នុងស្រុក ទោះបីជាថ្លៃទំនិញនៅទីផ្សារអន្តរជាតិមានការឡើងថ្លៃខ្លាំងក៏ដោយ ជាពិសេសថ្លៃប្រេងឥន្ធនៈដែលជាទំនិញនាំចូលសុទ្ធសាធរបស់កម្ពុជា ហើយក៏ជាទំនិញដែលមានឥទ្ធិពលខ្លាំងលើថ្លៃទំនិញដ៏ទៃទៀតផងនោះ ។




គិតតាមបម្រែបម្រួលខែលើខែ នាខែកញ្ញា ឆ្នាំ ២០១០ នេះ ក្នុងចំណោមថ្លៃទំនិញទាំង១២ក្រុម មាន ៩ក្រុមបានកើនឡើង ២ក្រុមបានថយចុះ និង១ក្រុមមិនមានការប្រែប្រួល ។ ក្រុមទំនិញដែលបានឡើងថ្លៃមានក្រុមគមនាគមន៍ ៥,៧% ក្រុមភោជនីយដ្ឋាន ១,៩% ក្រុមម្ហូបអាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង ១,១% ក្រុមសម្លៀកបំពាក់ និងស្បែកជើង ០,៩% ក្រុមទំនិញនិងសេវាផ្សេងៗ ០,៩% ក្រុមការកម្សាន្តនិងវប្បធម៌ ០,៨% ក្រុមដឹកជញ្ជូន ០,៧% ក្រុមសុខាភិបាល ០,៦% និងក្រុមគ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់គ្រួសារ និងការថែទាំផ្ទះជាប្រចាំ ០,៤% ។ ចំណែកឯង

ពិនិត្យលើបម្រែបម្រួលឆ្នាំលើឆ្នាំ ក្រាហ្វខាងក្រោម-ឆ្វេងបានបង្ហាញថា អត្រាអតិផរណាឆ្នាំលើឆ្នាំបានកើនឡើងជាសន្សឹមៗ២ខែជាប់គ្នាវិញ បន្ទាប់ពីបន្ថយល្បឿនកំណើនជាបន្តបន្ទាប់ក្នុងអំឡុង ៥ ខែជាប់គ្នា ចាប់ពីខែមីនាដល់ខែកក្កដា រួចមក ។ ជាក់ស្តែង នាខែសីហា និងខែកញ្ញា ឆ្នាំ ២០១០នេះ អត្រាអតិផរណាកើនដល់ ១,៨% និង ១,៩% រៀងគ្នា បន្ទាប់ពីបានថយចុះបន្តបន្ទាប់ដល់ម្រិតទាបជាងគេមួយក្នុងអំឡុង៩ខែមកនេះ ស្មើ ១,៦% កាលពីខែកក្កដា ។







កត្តាមួយចំនួនដែលបានរួមចំណែកក្នុងអតិផរណារួមប្រចាំឆ្នាំ នាខែកញ្ញា ឆ្នាំ២០១០ ដែលស្មើនឹង ១,៩% គឺ ក្រុមម្ហូបអាហារ និងភេសជ្ជៈពុំមានជាតិស្រវឹងមានចំណែក ១% (ត្រូវនឹងសមាមាត្រ ៥២,២% នៃអត្រាអតិផរណាប្រចាំឆ្នាំ) ក្រុមផ្ទះសម្បែង ទឹក អគ្គិសនី ឧស្ម័ន និង ឥន្ធនៈដទៃទៀតមានចំណែក ០,៤% (ត្រូវនឹងសមាមាត្រ ១៨,១% នៃអត្រាអតិផរណាប្រចាំឆ្នាំ) ក្រុមដឹកជញ្ជូនមានចំណែក ០,៣% (ត្រូវនឹងសមាមាត្រ ១៧,២% នៃអត្រាអតិផរណាប្រចាំឆ្នាំ) ក្រុមភោជនីយដ្ឋាន មានចំណែក ០,១% (ត្រូវនឹងសមាមាត្រ ៣,២% នៃអត្រាអតិផរណាប្រចាំឆ្នាំ) ។ រីឯក្រុមសុខាភិបាលដែលមានមេគុណចំនួន ៥% នៅក្នុងកន្ត្រកថ្លៃទំនិញប្រើប្រាស់មានចំណែកអវិជ្ជមាន ។ ដោយឡែក មុខទំនិញ៧ក្រុមទៀត ដែលនៅសល់បានចូលរួមចំណែក ០,២% ប៉ុណ្ណោះ (ត្រូវនឹងសមាមាត្រ ១២,៤% នៃអត្រាអតិផរណាប្រចាំឆ្នាំ) ។

| Contribution (YOY%) | Jul-10 | Aug-10 | Sep-10 |
|---|---|---|---|
| All Items | 1.6 | 1.8 | 1.9 |
| Food & N A B | 0.6 | 0.9 | 1.0 |
| Housing W E. | 0.6 | 0.5 | 0.4 |
| Transportation | 0.6 | 0.3 | 0.3 |
| Restaurants | -0.1 | 0.0 | 0.1 |
| Health | -0.1 | -0.1 | -0.1 |
| Others | 0.2 | 0.2 | 0.2 |

ទន្ទឹមនោះ ខណៈដែលអតិផរណារួមមានអត្រា ១,៩% ក្នុងខែកញ្ញានេះ អតិផរណាឆ្នាំលើឆ្នាំមិនគិតថ្លៃទំនិញក្រុមម្ហូបអាហារមានអត្រា ១,៦% ។ ទិន្នន័យនេះបង្ហាញថា ថ្លៃទំនិញក្រុមម្ហូបអាហារក្នុងខែកញ្ញា បានចូលរួមជំរុញឲ្យអតិផរណារួមកាន់តែមានកម្រិតខ្ពស់ឡើង ។ ដោយឡែកអតិផរណាឆ្នាំលើឆ្នាំមិនគិតថ្លៃទំនិញ និងសេវាដែលពាក់ព័ន្ធនឹងថ្លៃប្រេងឥន្ធនៈដែលមានបញ្ចូលទាំងថ្លៃសេវាក្រុមដឹកជញ្ជូនផងនោះ មានអត្រាត្រឹម ១,២% ពោលគឺទាបជាងអតិផរណារួមផងដែរ ដែលជាការឆ្លុះបញ្ចាំងឲ្យឃើញថា បម្រែបម្រួលថ្លៃទំនិញក្រុមនេះក៏ជាប្រភពនៃការកើនឡើងអតិផរណារួមប្រចាំឆ្នាំក្នុងខែកញ្ញានេះ ហើយក៏អាចជះឥទ្ធិពលដល់ការឡើងថ្លៃទំនិញនិងសេវាដទៃទៀត ។ ជាការពិត អត្រាអតិផរណាមិនរាប់បញ្ចូលទាំងក្រុមម្ហូបអាហារ និងទាំងថ្លៃទំនិញនិងសេវា ដែលពាក់ព័ន្ធនឹងថ្លៃប្រេងឥន្ធនៈផងនោះ មានកម្រិតអវិជ្ជមានដល់ -0,២% ពោលគឺបើពុំគិតបញ្ចូលថ្លៃស្បៀង និងឥន្ធនៈ ទំនិញជាទូទៅផ្សេងៗទៀតពុំមានការឡើងថ្លៃឡើយ ដែលអាចផ្តល់ការសន្និដ្ឋានថា តម្រូវការក្នុងស្រុករបស់អ្នកប្រើប្រាស់នៅមានកម្រិតទាប ស្របតាមសន្ទុះនៃសេដ្ឋកិច្ចដែលពុំទាន់មានល្បឿនលឿនដូចមុនពេលមានវិបត្តិពិភពលោក ។




## II- កត្តាសំខាន់ៗនៃអតិផរណា

### ១-កត្តាទំនិញ ៖

*ទី១-កត្តាថ្លៃម្ហូបអាហារ នឹងប្រេងឥន្ធនៈ:*

ម្ហូបអាហារមានកម្រិតមេគុណ ៤៥% ដែលខ្ពស់ជាងគេនៅក្នុងកន្ត្រកទំនិញ-សេវាសម្រាប់គណនាអតិផរណា ។ ជាទូទៅ ថ្លៃស្បៀង និងអតិផរណារួមហាក់មានទំនាក់ទំនងយ៉ាងជិតស្និទ្ធនឹងគ្នា ដូចក្រាហ្វខាងស្តាំបង្ហាញ ។




ទន្ទឹមនោះ ថ្លៃប្រេងឥន្ធនៈផ្ទាល់មានទម្ងន់ ១៦% នៅក្នុងកន្ត្រកទំនិញ-សេវា និងអាចមានឥទ្ធិពលបន្តទៅលើទំនិញដ៏ទៃយ៉ាងលឿនទៀតផង ។

ក្នុងខែកញ្ញា ឆ្នាំ២០១០ នេះ ថ្លៃប្រេងសាំងលើទីផ្សារពិភពលោកមានកម្រិត ៥២ សេនដុល្លារអាមេរិក ក្នុង ១ លីត្រ គឺបានកើនឡើង ៩% បើធៀបនឹងខែដូចគ្នាក្នុងឆ្នាំ២០០៩ ។ ការនេះបានធ្វើឱ្យថ្លៃប្រេងក្នុងស្រុកមានកម្រិត ១,០៥ ដុល្លារអាមេរិក ក្នុង ១លីត្រ ក្នុងខែកញ្ញានេះដែរ ពោលគឺបានកើនឡើង ១១% ធៀបនឹងខែដូចគ្នា នាឆ្នាំមុន ។

*ទី២- កត្តាអតិផរណានៃប្រទេសជិតខាង និងនៃទំនិញនាំចូល*

ក្នុងភាពជាអ្នកពឹងផ្អែកលើទំនិញនាំចូលសម្រាប់បំពេញតម្រូវការប្រើប្រាស់ក្នុងប្រទេស អតិផរណាក្នុងស្រុកក៏ត្រូវរងសម្ពាធថ្លៃទំនិញនៃប្រទេសនាំចូលដែរ ។ បច្ចុប្បន្ន ប្រទេសដែលជាដៃគូរពាណិជ្ជកម្មសំខាន់របស់កម្ពុជា គឺ ចិន ថៃ និងវៀតណាម ។ ជាគោលការណ៍ បម្រែបម្រួលអតិផរណានៅក្នុងប្រទេសទាំងនោះនឹងមានឥទ្ធិពលមកលើកម្រិតអតិផរណារបស់កម្ពុជា ។ សម្ពាធអតិផរណានៅប្រទេសចិនបង្ហាញនូវការកើនឡើងជាលំ-ដាប់ជាពិសេសនាអំឡុងឆមាសទីពីរ ។ អតិផរណានៅប្រទេសវៀតណាមមានកម្រិតខ្ពស់ ដោយមានអត្រាមធ្យមប្រចាំឆ្នាំប្រមាណ ៩% ។ ដោយឡែក អតិផរណានៅប្រទេសថៃមានស្ថិរភាពក្នុងកម្រិតប្រមាណ ៣,៤% ។ កម្រិតអតិផរណានៃប្រទេសទាំងបីនេះ ប្រសិននៅបន្តទៀតនោះនឹងអាចមានផលប៉ះពាល់ថែមទៀតលើថ្លៃទំនិញក្នុងស្រុកនៅកម្ពុជា ។

ទន្ទឹមនោះដែរ ដោយកម្ពុជាជាប្រទេសដុល្លារូបនីយកម្ម បម្រែបម្រួលនៃអត្រាប្តូរប្រាក់ដុល្លាអាមេរិកជាមួយប្រាក់យ៉ន់ចិន ប្រាក់បាតថៃ និងប្រាក់ដុងវៀតណាម ក៏មានឥទ្ធិពលផងដែរ មកលើកម្រិតអតិផរណារបស់ប្រទេសកម្ពុជា ។ ការឡើងថ្លៃជាលំដាប់នៃប្រាក់យ៉ន់ចិន និងប្រាក់បាតថៃធៀបនឹងប្រាក់ដុល្លាអាមេរិកមានអំណោយផលមិនល្អចំពោះអតិផរណាក្នុងស្រុករបស់កម្ពុជា ។

**២- កត្តាតម្រូវការ និងរូបិយវត្ថុ** : សភាពប្រសើរឡើងនៃទិដ្ឋភាពសេដ្ឋកិច្ចសកលលោក រួមទាំងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា បានចូលរួមបង្កើនទំនុកចិត្តវិស័យឯកជនមកលើប្រព័ន្ធធនាគារ ហើយបានរួមចំណែកធ្វើឲ្យការអភិវឌ្ឍរូបិយវត្ថុក្នុងប្រទេសមានសន្ទុះជាធម្មតាឡើងវិញ ។ ការវិវឌ្ឍប្រសើរឡើងនៃសូចនាកររូបិយវត្ថុសំខាន់ៗត្រូវបានឆ្លុះបញ្ចាំងដូចខាងក្រោម ៖

- អត្រាកំណើនរូបិយវត្ថុទូទៅ (M2) ឆ្នាំលើឆ្នាំ នាខែកញ្ញា ឆ្នាំ២០១០ នេះ ស្មើ ២៧% ធៀបនឹង ២៩% នាខែសីហា កន្លងទៅ ។ រូបិយវត្ថុទូទៅនេះធ្លាប់មានកំណើនត្រឹមតែ ១៩% ប៉ុណ្ណោះ នាខែកញ្ញា ឆ្នាំ២០០៩ និងមានកំណើនស្មើគ្នា នាខែដូចគ្នា ឆ្នាំ២០០៨ ។ ប្រភពចម្បងនៃកំណើនក្នុងខែកញ្ញា ឆ្នាំ២០១០ នេះ គឺប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស ដែលមានកំណើន ៣០% ហើយបានរួមចំណែក ២៤% ទៅក្នុងរូបិយវត្ថុទូទៅ ២៧% នោះ ។

- អត្រាកំណើនប្រចាំឆ្នាំនៃទ្រព្យសកម្មបរទេសសុទ្ធស្មើ ២២% នាខែកញ្ញា ឆ្នាំ២០១០ ដែលជាកំណើនមួយទាបជាងកំណើន ២៥% នៃខែសីហាកន្លងទៅ ។ ទ្រព្យសកម្មបរទេសសុទ្ធធ្លាប់មានកំណើនដល់ទៅ ២៨% នាគ្រាដូចគ្នា ឆ្នាំ២០០៩ និងមានកំណើនត្រឹមតែ ២០% ប៉ុណ្ណោះ នាខែដូចគ្នា ឆ្នាំ២០០៨ ។ ប្រភពចម្បងនៃកំណើននេះគឺ កំណើនទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារជាតិនៃកម្ពុជា ដែលរួមចំណែក ១៥% នៃកំណើនរូបិយវត្ថុទូទៅ (M2) និងទ្រព្យសកម្មបរទេសសុទ្ធរបស់គ្រឹះស្ថានធនាគារ ដែលរួមចំណែក ៦% នៃកំណើនរូបិយវត្ថុទូទៅ (M2) ។ ក្នុងរយៈពេលប្រាំបួនខែដើមឆ្នាំ២០១០នេះ ទ្រព្យសកម្មបរទេសសុទ្ធមានអត្រាកំណើនមធ្យមប្រចាំឆ្នាំស្មើនឹង ៣៣% ធៀបនឹងអត្រាកំណើនមធ្យមប្រចាំឆ្នាំ ១៨% នារយៈពេលដូចគ្នាឆ្នាំ ២០០៩ ។







- ប្រាក់បញ្ញើអតិថិជនក្នុងប្រព័ន្ធធនាគារនៅខែកញ្ញានេះ មានអត្រាកំណើនឆ្នាំលើឆ្នាំស្មើនឹង ៣០% ទាបជាងអត្រាកំណើននៅខែសីហា ឆ្នាំ២០១០ ដែលអត្រាកំណើននេះមានត្រឹម ១៩% នាគ្រាដូចគ្នា ឆ្នាំ២០០៩ ។ បើគិតជាមធ្យម អត្រាកំណើនប្រចាំឆ្នាំនៃប្រាក់បញ្ញើសរុបរយៈពេលប្រាំបួនខែដើមឆ្នាំ២០១០នេះ ស្មើនឹង ៣៨% ធៀបនិងកំណើន ៨% នារយៈពេលដូចគ្នាឆ្នាំ២០០៩ ។

- អត្រាកំណើនឆ្នាំលើឆ្នាំនៃឥណទានចំពោះវិស័យឯកជនមានល្បឿនកើនឡើងជាបន្តបន្ទាប់ក្នុងរយៈពេលប្រាំបួនខែចុងក្រោយនេះ ដែលក្នុងអំឡុងពេលពីរខែនេះ គឺខែសីហា និងខែកញ្ញា ឆ្នាំ២០១០ មានកំណើនស្មើគ្នា ២៣% ហើយកំណើននេះមានកំរិតត្រឹមតែ ៤% នាគ្រាដូចគ្នា ឆ្នាំ២០០៩ ។ បើគិតតាមអត្រាកំណើនមធ្យមប្រចាំឆ្នាំវិញ ក្នុងរយៈពេលប្រាំបួនខែឆ្នាំ២០១០នេះ ឥណទានចំពោះវិស័យឯកជនមានកំណើនស្មើនឹង ១៧% ដូចគ្នានឹងកំណើន នារយៈពេលដូចគ្នាឆ្នាំ២០០៩ ដែរ។




- ទុនបម្រុងផ្លូវការសុទ្ធ គិតត្រឹមថ្ងៃ ២៦ ខែតុលា ឆ្នាំ២០១០ នេះ មានទំហំ ២.៤៣១,៩ លានដុល្លារ ពោលគឺ បានកើនឡើងចំនួន ១៧១ លានដុល្លារ បើធៀបនឹងដំណាច់ឆ្នាំ២០០៩ ។ ទន្ទឹមនោះដែរ ទុនបម្រុងអន្តរជាតិដុលមានទំហំ ២.៥៣៩,៧ លានដុល្លារ ពោលគឺបានកើនឡើងប្រមាណ ១៧១,៥ លានដុល្លារ ធៀបនឹងដំណាច់ឆ្នាំ ២០០៩ ។ កំណើននេះ ជាចម្បងបានមកពីកំណើនជាចង្កោមនៃទុនបំរុងកាតព្វកិច្ចចំនួន ៨៩,៩ លានដុល្លារ ប្រាក់ធានាលើដើមទុនរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុចំនួន ២២,៨ លានដុល្លារ និងការប្រាក់ពីការវិនិយោគទុនបម្រុងអន្តរជាតិចំនួន ១៨,១ លានដុល្លារ ។ មិនគិតថ្លៃមាស ទុនបម្រុងផ្លូវការសុទ្ធមានទំហំ ១.៨៩៥,៨ លានដុល្លារ ពោលគឺបាន កើនឡើង ៧៣,២% ធៀបនឹងការថយចុះ ១៩,៧% នារយៈពេលដូចគ្នាឆ្នាំ២០០៩ ។

## III. ជំហរគោលនយោបាយរូបិយវត្ថុ និងសកម្មភាពចំពោះមុខ

### ១.បរិបទនៃប្រទេសជិតខាងនិងសកលលោក




ទិន្នន័យពីទស្សនទានសេដ្ឋកិច្ចសកលលោកដែលមូលនិធិរូបិយវត្ថុបានធ្វើបច្ចុប្បន្នកម្មនាខែតុលាឆ្នាំ ២០១០ បានបង្ហាញឲ្យឃើញថា កំណើនសេដ្ឋកិច្ចសកលលោក សេដ្ឋកិច្ចប្រទេសជឿនលឿន និងសេដ្ឋកិច្ចប្រទេសកំពុងងើបឡើងនិងកំពុងអភិវឌ្ឍន៍អាចនឹងកើនរហូតដល់ ៤,៨% ២,៧% និង៧,១% ប្រសើរជាងការព្យាករណ៍នាខែកក្កដាឆ្នាំ២០១០ ដែលថាកំណើនសេដ្ឋកិច្ចប្រទេសទាំងនោះមានត្រឹមតែ ៤,៦% ២,៦% និង ៦,៨% រៀងគ្នា នៅឆ្នាំ២០១០ តែប៉ុណ្ណោះ ។ សហរដ្ឋអាមេរិកដែលជាក្បាលម៉ាស៊ីនសេដ្ឋកិច្ចសកលោករំពឹងថានឹងមានកំណើនរហូតដល់២,៧%សម្រាប់ឆ្នាំ២០១០នេះ ខណៈដែលកំណើនសេដ្ឋកិច្ចប្រទេស ចិន ឥណ្ឌា និងសេដ្ឋកិច្ចឧស្សាហកម្មថ្មីៗនៅអាស៊ី និងអាស៊ាន-៥ នឹងឈានដល់ ១០,៥% ៩,៧% ៧,៨% និង ៦,៧% នៅឆ្នាំ២០១០ ។

អតិផរណាជាមធ្យមរបស់ប្រទេសជឿនលឿនដូចជាសហរដ្ឋអាមេរិក អឺរ៉ុប អាឡឺម៉ង់ ស្មើនឹង១,១៣% ១,៦៣% និង១,០៨% ក្នុងអំឡុងខែមិថុនា-កញ្ញាឆ្នាំ២០១០ ។ ជារួម ចាប់ពីខែសីហា ឆ្នាំ២០១០ មក ប្រទេសជាច្រើន រួមទាំងប្រទេសជឿនលឿននិងអាស៊ានបានរក្សាអត្រាការប្រាក់គោលរបស់គេនៅថេរដដែល ។ ពោលគឺ សហរដ្ឋអាមេរិក សហគមន៍អឺរ៉ុប បានរក្សាអត្រាការប្រាក់គោលនយោបាយរូបិយវត្ថុរបស់គេនៅថេរក្នុងកម្រិត ០,២៥% ក្នុងអំឡុងខែមករាឆ្នាំ២០០៩-ខែតុលា ឆ្នាំ២០១០ និង១%ក្នុងអំឡុងខែឧសភាឆ្នាំ២០០៩-ខែតុលាឆ្នាំ២០១០ រៀងគ្នា ។ ចំណែកឯប្រទេសថៃ ឥណ្ឌា និងម៉ាឡេស៊ីបានរក្សាអត្រាការប្រាក់គោលនយោបាយរូបិយវត្ថុឲ្យនៅថេរក្នុងកម្រិត ១,៧៥% ៥,៧៥% និង ២,៧៥% ចាប់ខែសីហាមកទល់នឹងតុលា ឆ្នាំ២០១០ រៀងគ្នាបន្ទាប់បានអនុវត្តន៍គោលនយោបាយរឹតត្បិតរបស់ខ្លួនកាលពីគ្រាមុនរួចមក ។ ដោយឡែក ប្រទេសចិន និងវៀតណាមបានចាប់ផ្តើមអនុវត្តន៍គោលនយោយរូបិយវត្ថុរឹតត្បិតដោយបង្កើនអត្រាការប្រាក់គោលនយោបាយរបស់ខ្លួនពី ៥,៣១% នៅខែកញ្ញាទៅ ៥,៥៦% នៅខែតុលានិងពី ៦% នៅខែកញ្ញាទៅ ៧% នៅខែតុលា ឆ្នាំ២០១០ រៀងគ្នា ។






២.បរិបទនៃប្រទេសកម្ពុជា

ក-ស្ថានភាពសេដ្ឋកិច្ច

- កំណើនសេដ្ឋកិច្ច

ឥទ្ធិពលអវិជ្ជមាននៃវិបត្តិសេដ្ឋកិច្ចសកលលោកដែលបានកើតឡើងចាប់ពីចុងឆ្នាំ២០០៧ មានការថមថយចុះជាច្រើន ជាពិសេសសេដ្ឋកិច្ចប្រទេសនៅអាស៊ី ។ សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករណ៍ថានឹងមានកំណើនប្រចាំឆ្នាំ៥,៥%នៅឆ្នាំ២០១០ ដែលជួយរុញច្រានដោយកំណើនវិស័យកសិកម្មចំនួន២,៣% ឧស្សាហកម្ម៥,៧% និងវិស័យសេវាកម្មចំនួន ២,៤% ។ ម្យ៉ាងវិញទៀត រូបិយវត្ថុអន្តរជាតិក៏បានគូសបញ្ជាក់ឲ្យដឹងផងដែរថា កំណើនសេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០១០នេះស្ថិតក្នុងចន្លោះពី ៤,៥%-៥% ដោយសារការងើបឡើងវិញនៃកំណើននៃការនាំចេញសំលៀកបំពាក់ និងកំណើនភ្ញៀវទេសចរណ៍បរទេស ។ ជាក់ស្តែង ទិន្នន័យថ្មីៗបានបង្ហាញថាការនាំចេញ និងការវិនិយោគផ្ទាល់បរទេស(សុទ្ធ)បានកើនឡើងរហូតដល់ជិត ១៥% និងជិត ៣៨% រៀងគ្នានៅក្នុងឆមាសទីមួយឆ្នាំ ២០១០ ធៀបនឹងរយៈពេលដូចគ្នានាឆ្នាំ ២០០៩ ។ ចំណែកឯចំនួនភ្ញៀវទេសចរណ៍មកទស្សនកិច្ចនៅកម្ពុជាក៏បានកើនឡើងគួរឲ្យកត់សំគាល់រហូតដល់ប្រហែល ១៥% នៅក្នុង ៨ ខែដើមឆ្នាំ២០១០ នេះធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ ២០០៩ ។

- ស្ថានភាពអត្រាប្តូរប្រាក់




នៅពេលប្រាក់រៀលបានធ្លាក់ថ្លៃជាបន្តបន្ទាប់ធៀបនឹងប្រាក់ដុល្លារអាមេរិក ធនាគារជាតិនៃកម្ពុជា បានធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់តាមរយៈការលក់ប្រាក់ដុល្លារចំនួន ៤៨ដង ដែលមានទឹកប្រាក់ ៤៨ លានដុល្លារ ដែលត្រូវនឹង ២០៣.៣៨២ លានរៀល ពីខែឧសភា មកត្រឹមថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០ ។ ជាលទ្ធផល បើគិតតាមបម្រែបម្រួលមធ្យមប្រចាំខែ ក្នុងរយៈពេល១០ខែដើមឆ្នាំ២០១០ នេះ អត្រាទិញទីផ្សារចុងគ្រារបស់ប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក បានចុះថ្លៃត្រឹមតែ ១,៥៧ % ធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំមុន ។

នៅក្នុងអំឡុងពេលដូចគ្នានេះដែរ បើធៀបនឹងរូបិយប័ណ្ណនៃបណ្តាប្រទេសជាដៃគូពាណិជ្ជកម្មមួយចំនួន ប្រាក់រៀលបានចុះថ្លៃ ១០,០៣% ៨,០១% ១,៨២% និង ១,២៥% ធៀបនឹងប្រាក់រីងហ្គីតម៉ាឡេស៊ី ប្រាក់បាតថៃ ប្រាក់យ៉ន់ចិន និងប្រាក់ដុល្លារហុងកុង រៀងគ្នា ធៀបនឹងរយៈពេលដូចគ្នានាឆ្នាំ២០០៩ ។ ផ្ទុយទៅវិញ ប្រាក់រៀលបានឡើងថ្លៃជាមធ្យម ៥,៣០% ធៀបនឹងប្រាក់ដុងវៀតណាមនារយៈពេលដូចគ្នានេះ ។

- ចលនាអត្រាការប្រាក់

កំណើនប្រាក់បញ្ញើអតិថិជនបានធ្វើឲ្យស្ថានភាពសាច់ប្រាក់ងាយស្រួលរបស់ប្រព័ន្ធធនាគារមានភាពប្រសើរឡើងជាច្រើនធៀបនឹងឆ្នាំ ២០០៨-២០០៩ ។ នៅចំពោះមុខសភាពការណ៍នេះ គ្រឹះស្ថានធនាគារក៏បានសម្រេចបញ្ចុះអត្រាការប្រាក់បញ្ញើនិងប្រាក់កម្ចីជាបន្តបន្ទាប់ចាប់តាំងពីដើមឆ្នាំ២០០៩មកម្ល៉េះ។ បច្ចុប្បន្ននេះ អត្រាការប្រាក់ថ្លឹងរយៈពេល៦ខែចំពោះប្រាក់បញ្ញើជារៀលស្ថិតនៅក្នុងកម្រិត ៥,៥% ដដែល និងជាដុល្លារបានថយចុះពី ៣,៩ មក ៣,៧% នៅខែកញ្ញា ឆ្នាំ ២០១០ ។ ចំណែកឯអត្រាការប្រាក់មធ្យម សម្រាប់ធនាគារធំៗចំនួន១០ ចំពោះប្រាក់បញ្ញើជារៀលនិងជាដុល្លារស្មើ ៥,៤% និង ៣,៤% រៀងគ្នានៅក្នុងរយៈពេលដូចគ្នា ។ ក្នុងអំឡុងពេលដូចគ្នានេះដែរ អត្រាការប្រាក់ថ្លឹងរយៈពេល៦ខែចំពោះប្រាក់កម្ចីជារៀលនិងជាដុល្លារស្មើនឹង ២២,៣% និង១៧,២% រៀងគ្នា ។ ម្យ៉ាងវិញទៀត អត្រាការប្រាក់មធ្យមសម្រាប់ធនាគារធំៗចំនួន១០ ចំពោះប្រាក់កម្ចីជារៀល និងជាដុល្លារស្មើនឹង ២១% និង ១៦,១% រៀងគ្នានៅក្នុងរយៈពេលដូចគ្នា ។




- ស្ថានភាពឥណទានមិនដំណើរការ

ដូចក្រាហ្វខាងស្តាំបានបង្ហាញ កំណើនឥណទានរបស់គ្រឹះស្ថានធនាគារបានបន្តកើនឡើងជាលំដាប់បន្ទាប់ពីមានអត្រាទាបត្រឹម ២,៧% កាលពីខែវិច្ឆិកាឆ្នាំ ២០០៩។ មកដល់ខែកញ្ញា ឆ្នាំ ២០១០ នេះ ឥណទានចំពោះវិស័យឯកជនបានកើនឡើងដល់២៣,២%ធៀបនឹងគ្រាដូចគ្នានៃឆ្នាំមុន ខណៈដែលកម្រិតឥណទានមិនដំណើរការមាននិន្នាការធ្លាក់ចុះបន្តិច ។ នេះបង្ហាញឲ្យឃើញថា គ្រឹះស្ថានធនាគារមានការប្រុងប្រយ័ត្នក្នុងការឲ្យខ្ចី ដែលធ្វើឲ្យឥណទានមិនដំណើរការមានការប្រែប្រួលក្នុងរង្វង់ ៤,៤% ប៉ុណ្ណោះក្នុងរយៈពេល១០ខែកន្លងមកនេះ។

